FACTSHEET

ក្រសួងអប់រំរដ្ឋ NSW

Student use of mobile phones in schools

Information for parents and carers

# សិស្សប្រើទូរសព្ទដៃនៅសាលារៀន

ព័ត៌មានសម្រាប់ឪពុកម្ដាយ និងអ្នកថែទាំ

## ការហាមឃាត់មិនឱ្យប្រើទូរសព្ទដៃនៅក្នុងសាលាមធ្យមសិក្សា ឥឡូវនេះត្រូវបានដាក់ដំណើរការហើយ

ការហាមឃាត់មិនឱ្យប្រើទូរសព្ទដៃនៅក្នុងសាលាមធ្យមសិក្សា សាងសង់លើការហាមឃាត់ដែលបានដាក់ដំណើរការរួចហើយនៅក្នុងសាលាបឋមសិក្សារដ្ឋក្នុងរដ្ឋ NSW។

ការហាមឃាត់នេះអនុវត្តក្នុងអំឡុងថ្នាក់រៀន ពេលសម្រាក និងពេលអាហារថ្ងៃត្រង់។ សិស្សត្រូវបានអនុញ្ញាតឱ្យកាន់យកទូរសព្ទខណៈពេលកំពុងធ្វើដំណើរទៅ និងមកពីសាលារៀន។

នាយកសាលា និងគ្រូបង្រៀន ក៏អាចអនុញ្ញាតឱ្យប្រើទូរសព្ទដៃសម្រាប់គោលបំណងអប់រំ ឬជាផ្នែកនៃការកែតម្រូវសមហេតុផលសម្រាប់ការរៀនសូត្រ និងសុខុមាលភាពរបស់សិស្សផងដែរ។

ដើម្បីគាំទ្រដល់ការណែនាំនៃការហាមឃាត់នេះ ក្រសួងអប់រំរដ្ឋ NSW បានស្នើសុំឱ្យសាលារៀនពិគោះយោបល់ជាមួយសហគមន៍មូលដ្ឋាននានារបស់ពួកគេ អំពីជម្រើសនៃការអនុវត្តជាច្រើន។

ជម្រើសទាំងនេះរួមមាន៖

**បិទ និងដាក់ឱ្យឆ្ងាយ៖** ត្រូវបិទទូរសព្ទ និងដាក់ឱ្យឆ្ងាយ (ជាធម្មតានៅក្នុងកាបូបសិស្ស)។ មិនត្រូវប្រើទូរសព្ទសម្រាប់រយៈពេលនៃថ្ងៃសិក្សាទេ។

**ទូរសព្ទរក្សាទុកនៅក្នុងទូមានសោ៖** សិស្សមិនត្រូវកាន់យកទូរសព្ទទៅជាមួយពួកគេទេ។ ពួកគេត្រូវតែរក្សាវាទុកនៅក្នុងទូមានសោសម្រាប់រយៈពេលនៃថ្ងៃសិក្សា។

**កូនថង់ដាក់ទូរសព្ទចាក់សោ៖** សិស្សដាក់ទូរសព្ទរបស់ពួកគេនៅក្នុងកូនថង់ចាក់សោដោយមេដែក ហើយមិនអាចប្រើទូរសព្ទរបស់ពួកគេក្នុងរយៈពេលនៃថ្ងៃសិក្សាបានទេ។ កូនថង់ត្រូវបានដោះសោដោយមេដែកនៅចុងថ្ងៃសិក្សា។

**ទូរសព្ទត្រូវបានប្រមូលនៅការិយាល័យខាងមុខ៖** សិស្សដាក់ទូរសព្ទរបស់ពួកគេនៅការិយាល័យខាងមុខរបស់សាលា នៅពេលចាប់ផ្តើមថ្ងៃសិក្សា ហើយប្រមូលវានៅចុងបញ្ចប់នៃថ្ងៃសិក្សា (ឬនៅពេលចាកចេញពីបរិវេណសាលា)។

**ទូរសព្ទត្រូវបានប្រមូលនៅពេលចាប់ផ្តើមមេរៀន៖** ទូរសព្ទត្រូវបានប្រមូល និងរក្សាទុកដោយគ្រូនៅពេលចាប់ផ្តើមមេរៀន ហើយប្រគល់ជូនសិស្សវិញនៅពេលបញ្ចប់មេរៀន និង/ឬនៅពេលសិស្សចេញពីថ្នាក់រៀន។

សហគមន៍សាលាដោយឡែកនីមួយៗបានសម្រេចចិត្ត ថាតើជម្រើសមួយណាដែលពួកគេនឹងជ្រើសយក សម្រាប់ការអនុវត្តនៃគោលនយោបាយនេះ។

## ការប្រាស្រ័យទាក់ទងរបស់សិស្សជាមួយឪពុកម្ដាយ និងអ្នកថែទាំក្នុងអំឡុងម៉ោងសិក្សា

ប្រហែលជាមានពេលខ្លះដែលឪពុកម្ដាយ ឬអ្នកថែទាំត្រូវការទាក់ទងមកសិស្ស ឬផ្ទុយទៅវិញ ក្នុងអំឡុងពេលថ្ងៃសិក្សា។ ឪពុកម្ដាយ និងអ្នកថែទាំអាចធ្វើទំនាក់ទំនងជាមួយសាលារៀនតាមរយៈការិយាល័យសាលា ហើយសិស្សក៏នឹងអាចទាក់ទងឪពុកម្ដាយ ឬអ្នកថែទាំតាមរយៈការិយាល័យសាលាផងដែរ ប្រសិនបើវាជារឿងបន្ទាន់។

### សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមទូរសព្ទទៅសាលារៀន។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ដើម្បីជួយអ្នកក្នុងការសាកសួររបស់អ្នក សូមទូរសព្ទមក សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទលេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។

ប្រាប់ការីទូរសព្ទនូវលេខទូរសព្ទដែលអ្នកចង់ហៅ ហើយការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់ម្នាក់ ដើម្បីជួយអ្នកក្នុងការសន្ទនា។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។

NSW GOVERNMENT